# កិច្ចព្រមព្រៀង ពាណិជ្ជកម្ម
# រវាង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង
# រាជរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់ និង
# យ៉ាងឌីប៉េទូអាននៃព្រះរាជាណាចក្រប្រ៊ុយណេដារ៉ុយសាឡឹម

❋❋❋❋❋❋❋

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រាជរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់ និង យ៉ាងឌីប៉េទូអាននៃព្រះរាជាណាចក្រប្រ៊ុយណេដារ៉ុយសាឡឹម ដែលបន្ទាប់ទៅនេះហៅកាត់ថា "ភាគីចុះហត្ថលេខា"

ក្នុងគោលបំណងពង្រឹងពង្រីកទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ផ្អែកលើមូលដ្ឋាននៃគោលការណ៍សមភាពមានផលប្រយោជន៍ទៅវិញទៅមក និង អត្ថប្រយោជន៍ដែលបានទទួលការអនុគ្រោះបំផុត ដើម្បីលើកកំពស់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ភាគីទាំងសងខាង

បានព្រមព្រៀងគ្នាដូចខាងក្រោម :

## ប្រការ ១

ភាគីចុះហត្ថលេខាទាំងពីរ ផ្អែកតាមក្របខណ្ឌច្បាប់ នឹងបទបញ្ញត្តិដែលមាន ត្រូវប្រកាន់យកវិធានការណ៍សមស្របដើម្បីសំរួលពង្រឹង និងធ្វើអោយកាន់តែសំបូរបែបឡើងនូវចំណងទាក់ទងពាណិជ្ជកម្ម រវាងប្រទេស ទាំងពីរ លើមូលដ្ឋានយូរអង្វែង និង មានស្ថិរភាព ។

## ប្រការ ២

ភាគីចុះហត្ថលេខាទាំងពីរ តាមប្រការនានានៃច្បាប់ និង បញ្ញត្តិជាធរមាន ក្នុងប្រទេសរបស់ខ្លួនត្រូវផ្តល់អោយគ្នាទៅវិញទៅមកនូវឋានៈជាប្រជាជាតិអនុគ្រោះបំផុត ចំពោះកាតព្វកិច្ចខាងពន្ធគយព្រមទាំងពន្ធនឹងអាករផ្សេងៗទៀត ដែលអនុវត្តចំពោះការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ដូចដែលបានព្រមព្រៀងដោយប្រទេសទាំងពីរ នៅក្នុងកិច្ចព្រមព្រៀងទូទៅ ស្តីពីពាណិជ្ជកម្ម និង ពន្ធគយ (GATT 1994) ។

ភាគីចុះហត្ថលេខាទាំងពីរ ត្រូវផ្តល់នូវប្រព្រឹត្តិកម្មជាតិ ចំពោះផលិតផលដែល នាំចូលពីប្រទេសណាមួយ ធៀបចំពោះផលិតផលក្នុងស្រុករបស់ខ្លួន ដោយផ្អែកទៅលើច្បាប់ បទបញ្ញត្តិ និងកាតព្វកិច្ចគំរូវផ្សេងៗ (រួមមានពន្ធលើការលក់ អត្រាប្តូរប្រាក់ ដែលបានកំណត់ និងការត្រួតពិនិត្យ ការផ្លាស់ប្តូរក្រៅប្រទេស ដែលប៉ះពាល់ដល់ការលក់ដូរ ក្នុងប្រទេស ការស្នើលក់ការទិញ ការដឹកជញ្ជូន ការបែងចែក ឬ ការប្រើប្រាស់ផលិតផលទាំងនោះ) ។

## ប្រការ ៣

ខនានានៃប្រការ ២ នឹងមិនត្រូវអនុវត្តក្នុងករណីដូចខាងក្រោម :

ក. ភាគីណាមួយក្នុងចំណោមភាគីចុះហត្ថលេខាទាំងពីរ បានទទួល ឬ សំរបសំរួលផលប្រយោជន៍របស់ខ្លួនចំពោះប្រទេសជិតខាងដើម្បីសំរួលការផ្លាស់ប្តូរពាណិជ្ជកម្ម ដោយកំណត់ត្រឹមលក្ខណៈនៃតំបន់ពាណិជ្ជកម្មតាមព្រំដែនដែលការធ្វើពាណិជ្ជកម្មនេះបានកើតឡើង នឹង

ខ. ផាត់ចេញនូវលក្ខណៈអនុគ្រោះនានា ដែលជាលទ្ធផលបានមកពីការធ្វើពាណិជ្ជកម្ម តាមរបៀបអនុគ្រោះណាមួយ ឬតាមការរៀបចំក្រុមសេដ្ឋកិច្ចក្នុងតំបន់ ដែលភាគីណាមួយនៃភាគីចុះហត្ថលេខាទាំងពីរជាសមាជិក ។

ពាណិជ្ជកម្មទំនិញនិងផលិតផលរវាងប្រទេសទាំងពីរ នឹង ត្រូវអនុវត្តផ្អែកតាមច្បាប់ និងបទបញ្ញត្តិជាធរមានរបស់ប្រទេសទាំងពីរ ។

## ប្រការ ៤

ភាគីចុះហត្ថលេខាទាំងពីរត្រូវព្រមព្រៀងគ្នា ដោយផ្អែកទៅតាមច្បាប់ និងបទបញ្ញត្តិជាធរមាន របស់ប្រទេសទាំងពីរ ដើម្បីសំរួលការចូលរួមក្នុងផ្សារណាត់ និង ពិពណ៌ព្រម ទាំងរៀបចំទស្សនៈកិច្ចរបស់ពាណិជ្ជករនៃមជ្ឈមណ្ឌលពាណិជ្ជកម្មនានា ។ លើកលែងពន្ធគយ និង អាករផ្សេងៗទៀត ដែលមានអត្ថន័យប្រហាក់ប្រហែលគ្នាចំពោះផលិតផល និង ទំនិញគំរូដែលប្រើប្រាស់សំរាប់ផ្សារណាត់ និង ការតាំងពិពណ៌ ក៏ដូចជាសំរបសំរួល ចេញ-ចូល ទំនិញ និងផលិតផលទាំងនេះ ។ ការលក់ និង ទុកដាក់ទំនិញទាំងនេះ ត្រូវគោរព ទៅតាមច្បាប់ និង បទបញ្ញត្តិនៃប្រទេសដែលផ្សារណាត់ ឬ ពិពណ៌ នោះ បានប្រព្រឹត្តិទៅ ។

## ប្រការ ៥

រាល់ការទូទាត់ថ្លៃទំនិញ និង សេវារវាងប្រទេសទាំងពីរ ត្រូវធ្វើឡើងដោយរូបិយបណ្ណ័ដែលអាចប្តូរ ផ្ទេរបានដោយសេរី ស្របតាមបទបញ្ញត្តិជាធរមាននៃប្រទេសទាំងពីរ ។

## ប្រការ ៦

ស្របតាមច្បាប់នឹងបទបញ្ញត្តិដែលមានភាគីចុះហត្ថលេខានិមួយៗ ត្រូវយល់ព្រមផ្តល់ដល់បុគ្គលនៃភាគីម្ខាងទៀតដោយផ្អែកតាមប្រការនានានៃកិច្ចព្រមព្រៀងនេះនូវជំនួយចាំបាច់ ដើម្បីសំរួលដល់ការបំពេញការងារ នឹងធានាអោយការអនុវត្តន៏ការងាររបស់គេ ទទួលបានជោគជ័យ ។

## ប្រការ ៧

អ្នកតំណាងនៃភាគីចុះហត្ថលេខាទាំងពីរនៅពេលមានសំណូមពរពីភាគីណាមួយត្រូវពិភាក្សាលើកឡើងនូវវិធានការណ៍ចាំបាច់សំដៅពង្រឹងពង្រីកទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ និង

លើកឡើងនូវជំលោះស្រាយលើរាល់បញ្ហាដែលកើតឡើងពីការអនុវត្តន៏កិច្ចព្រមព្រៀងនេះដោយឈរលើស្មារតីសហប្រតិបត្តិការ និង ការយោគយល់គ្នាទៅវិញទៅមក ។ ទីកន្លែង និង កាលបរិច្ឆេទនៃការពិភាក្សារបៀបនេះនឹងត្រូវកំណត់ឡើង ប្រសិនបើចាំបាច់ ដោយការយល់ព្រមទៅវិញទៅមក ។

## ប្រការ ៨

កិច្ចព្រមព្រៀងនាពេលបច្ចុប្បន្ននេះ នឹងមិនរារាំងដល់ភាគីណាមួយនៃភាគីចុះហត្ថលេខាទាំងពីរចំពោះការអនុវត្តន៏ការហាមឃាត់ ឬ ការដាក់កំហិត ដោយវិធានការណ៏ណាមួយ ដែលសំដៅការពារដោយផ្ទាល់នូវប្រយោជន៏សុវត្ថភាពជាសារវ័ន្ត សីលធិមសាធារណៈ សុខភាពសាធារណៈ ការការពារជំងឺផ្សេងៗ និង ការការពាររោគឆ្លងដល់សត្វពាហនៈ និងរុក្ខជាតិ ។ រាល់ការហាមឃាត់ ឬ ការដាក់ កំហិតនានាលើការធ្វើពាណិជ្ជកម្ម ត្រូវជូនដំណឹងគ្នាជាមុនជាលាយលក្ខ័អក្សរ ។

## ប្រការ ៩

ក្នុងករណីមានវិវាទ កើតឡើងចេញពីការបកស្រាយ ឬ ការអនុវត្តន៏ប្រការនានានៃកិច្ចព្រមព្រៀងនេះត្រូវដោះស្រាយដោយមិត្តភាពតាមផ្លូវការទូត រវាងប្រទេសចុះហត្ថលេខាទាំងពីរ ។

## ប្រការ ១០

កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន នៅពេលដែលភាគីចុះហត្ថលេខាទាំងពីរ បានជូនដំណឹងគ្នាទៅវិញទៅមកនឹងបានបញ្ចប់នូវរាល់បែបបទផ្ទៃក្នុងរបស់ខ្លួនហើយ ។ កិច្ចព្រមព្រៀងនេះមានសុពលភាពក្នុងរយៈពេល ០៥ ( ប្រាំ ) ឆ្នាំ ហើយនឹងត្រូវបានបន្តពន្យារពេលដោយស្វ័យប្រវត្តិសំរាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ទៀត លើកលែងតែមានភាគីណាមួយ ជូនដំណឹងជាលាយលក្ខ័អក្សរ អំពីគោលបំណងរបស់ខ្លួនក្នុងការបញ្ចប់កិច្ចព្រមព្រៀងនេះ ក្នុងរយៈ ពេល ០៣ (បី) ខែ មុនពេលកិច្ចព្រមព្រៀងនេះអស់សុពលភាព ។

មាត្រាទាំងឡាយនៃកិច្ចព្រមព្រៀងនេះនឹងអនុវត្តបន្ត ទោះបីកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ក៏ដោយ ចំពោះកិច្ចសន្យានានា ដែលបានធ្វើឡើងក្នុងរយៈពេលសុពលភាពនៃកិច្ចព្រមព្រៀងនេះ ហើយដែលមិនទាន់បានអនុវត្តចប់សព្វគ្រប់នៅថ្ងៃដែលកិច្ចព្រមព្រៀងនេះផុតសុពលភាព ។

ដោយយោលទៅតាមសំណូមពររបស់ភាគីណាមួយ កិច្ចព្រម ព្រៀងបច្ចុប្បន្នអាចបំពេញបន្ថែម ឬ កែប្រែ ដោយមានការយល់ព្រមពីភាគីទាំងសងខាង ។

ជាសក្ខីភាព អ្នកចុះហត្ថលេខាខាងក្រោមដោយបានទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខា លើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅរាជធានី បន់ដា សេរីប៊ីហ្គាវ៉ាន់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០០ ជា ០២ (ពីរ) ច្បាប់ដើម ជាភាសាខ្មែរ និង អង់គ្លេស ។ អត្ថបទទាំងពីរមានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយ ខុសគ្នា អត្ថបទជាភាសាអង់គ្លេស ត្រូវបានយកជាគោល ។

| | |
|---|---|
| **តំណាងរដ្ឋាភិបាល** | **តំណាងរដ្ឋាភិបាល** |
| **នៃព្រះរាជាណាចក្រកម្ពុជា** | **នៃព្រះចៅស៊ុលតង់ និង យ៉ាងឌីប៉េរ្សអាន** |
| | **នៃព្រះរាជាណាចក្រប្រ៊ុយណេដារ៉ុយសាឡឹម** |
| **ចម ប្រសិទ្ធ** | **ប៉េហ៊ិន ដាតូ ហាស្ស៊ី អាប់ឌុល រ៉ាម៉ាន់** |
| **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** | **រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង ប្រភពធនធាន** |